**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**

សាលក្រមលេខៈ ៣៩.. (ជ)

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

រឿងក្តីរដ្ឋប្បវេណីលេខ ៦៤៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០

ប្រភេទនៃរឿងក្តី ៖ បណ្តឹងសុំបញ្ជាក់សិទ្ធិអត្ថិភាពដី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃចន្ទ ០៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ពស.២៥៦៤

ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

បានចេញសាលក្រមដែលមានភាគី៖

**ដើមចោទ៖**

ឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៥៧ មានអាសយដ្ឋានផ្ទះលេខ [redacted]។

លោកមេធាវី [redacted] មេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក មានការិយាល័យនៅផ្ទះលេខ [redacted]។

**ចុងចម្លើយ ៖**

-ឈ្មោះ [redacted] ថេត ភេទប្រុស កើតឆ្នាំ១៩៨០ និងប្រពន្ធឈ្មោះ [redacted] ចាន់នី កើតឆ្នាំ១៩៨៥ អាសយដ្ឋានផ្ទះ [redacted]។

### អង្គហេតុ និងចំណុចទទាស

**ក. សាលក្រមដែលទាមទារដោយភាគី**

១-សុំទទួលស្គាល់សិទ្ធិអត្ថិភាពលើឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៨៧ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ។

២.ឲ្យឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៨៧ មានសិទ្ធិការផ្ទេរកម្មសិទ្ធិដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២៦ ខែ

កញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ពីម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] ថេត ភេទប្រុស កើតឆ្នាំ១៩៤០ និងប្រពន្ធឈ្មោះ [redacted] ចាន់នី កើតឆ្នាំ១៩៤៥។

៣-ឲ្យដើមចោទជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

**ខ. ការពន្យល់អង្គហេតុមានដូចតទៅ:**

អចលនវត្ថុនៃដីចំនួន០១កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ដែលមានឈ្មោះ [redacted] ចាន់ថេត និងឈ្មោះ [redacted] ចាន់នី ជាម្ចាស់កម្មសិទ្ធិករ ក្រោយមកឈ្មោះ [redacted] ចាន់ថេត និងឈ្មោះ [redacted] ចាន់នី បានព្រមព្រៀងលក់ដីនេះទៅឲ្យឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក តាមរយៈកិច្ចសន្យាលេខ ៧៤៧ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ របស់មេឃុំអូរដំបង២ និងលិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវលេខ ៧៤៦ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ ពិតមែន តែមិនអាចកាត់ប្លង់ឲ្យត្រឹមត្រូវតាមផ្លូវច្បាប់នៅឡើយទេ ។

**គ. អំពីចំណុចទខាន:**

- គ្មាន ។

**ការសំអាងហេតុ**

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី និងបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការយល់ឃើញថា ៖

១-ពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់ដើមចោទបានធ្វើឡើងក្នុងកំណត់ច្បាប់អាចលើករឿងនេះពិនិត្យនិង សម្រេចតាមបញ្ញាត្តិច្បាប់បាន ។

២-ដើមចោទទាមទារឲ្យតុលាការចេញសាលក្រម៖

២.១-សុំទទួលស្គាល់សិទ្ធិអត្ថិភាពលើដើមចោទឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៤៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៤៧ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ។

២.២.ឲ្យឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៤៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៤៧ មានសិទ្ធិការផ្ទេរកម្មសិទ្ធិដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ពីម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] ថេត ភេទប្រុស កើតឆ្នាំ១៩៤០ និងប្រពន្ធឈ្មោះ [redacted] ចាន់នី កើតឆ្នាំ១៩៤៥។

២.៣-ឲ្យដើមចោទជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

៣-ផ្អែកតាមការបញ្ជាក់ភស្តុតាងរួមមាន ៖

ក.កិច្ចសន្យាលេខ ៧៤៧ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ របស់មេឃុំអូរដំបង២ ដែលឈ្មោះ [redacted] ថេត និងប្រពន្ធឈ្មោះ [redacted] ចាន់នី សន្យានិងសុខចិត្តផ្តិតមេដៃផ្ទេរសិទ្ធិដីលេខ ៥៥២ ទំហំ១៥០.២ម៉ែត្រការ៉េ ធ្វើជាកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក ។

ខ.លិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវ លេខ ៧៤៦ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ របស់មេឃុំអូរដំបង២ បានបញ្ជាក់ថាឈ្មោះ [redacted] ថេត ភេទប្រុស អាយុ៧០ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ចាន់នី អាយុ៦៥ឆ្នាំ បានព្រមព្រៀងគ្នាផ្ទេរសិទ្ធិរោងម៉ាស៊ីនកិនស្រូវ និងដីរោងម៉ាស៊ីនលេខ ៥៥២ នៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២



Scanned with CamScanner

ស្រុកសង្កែ ខេត្តបាត់ដំបង ឲ្យទៅឈ្មោះ [redacted]ប៊ូ ភេទប្រុស អាយុ៦៧ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] យុក អាយុ៥៣ឆ្នាំ មានទំហំ១៩០២ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងអូរ ខាងកើតទល់នឹងដីលេខ ៣៧៦ និងខាងលិចទល់នឹងផ្លូវ ។

គ.បានឃើញ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ មានក្បាលដីលេខ ៥៥២ ទំហំ ១៩០២ម៉ែត្រការ៉េ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ថេត និងឈ្មោះ [redacted]ចាន់នី ស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង។

ឃ.បានឃើញ លិខិតបញ្ជាក់លេខ ៣៥ អប២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដែលបានបញ្ជាក់ថា ឈ្មោះ [redacted] ថេត ភេទប្រុស អាយុ៨១ឆ្នាំ និងប្រពន្ធឈ្មោះ [redacted]ចាន់នី អាយុ៧៦ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ [redacted] បានធ្វើលិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវលេខ ៧៤៦ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ មកឲ្យឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ ១៩៨៣ និងប្រពន្ធឈ្មោះ យី យុក កើតឆ្នាំ១៩៥៧ មានអាសយដ្ឋានផ្ទះលេខ[redacted] ហើយឈ្មោះ [redacted]ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក បានកាន់កាប់តាំងពីទិញហូត មកដល់ពេលបច្ចុប្បន្នពិតប្រាកដមែន ពុំមានតតិយជនណាមួយទាមទារទេ ចំណែកចុងចម្លើយបានទៅរស់នៅបរទេសអស់ហើយ ។

៤.តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក បានធ្វើសេចក្តីថ្លែងការណ៍ ចំពោះបណ្តឹងទាមទាររបស់ខ្លួនថា: កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១០ កូនក្តីខ្លួន និងប្រពន្ធបានទិញដីទំហំ ១៩០២ម៉ែត្រការ៉េ ក្បាលដីលេខ ៥៥២ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ បានធ្វើលិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវលេខ ៧៤៦ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ នៅចំពោះមុខមេឃុំអូរដំបង២ បន្ទាប់ពីធ្វើការទិញលក់ដីរួចហើយ កូនក្តីខ្លួន និងប្រពន្ធ ពុំទាន់បានកាត់ឈ្មោះតាមនីតិវិធីមន្ត្រីសុរិយោដីនោះទេ ទើបតែពេលនេះកូនក្តីខ្លួនចង់កាត់ឈ្មោះធ្វើជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ហើយកូនក្តីខ្លួនបានទៅការិយាល័យភូមិបាលស្រុក តែមន្ត្រីជំនាញ មិនអាចកាត់ឈ្មោះបាននោះទេ លុះត្រាតែមានសាលក្រមសម្រេចថា ប្រគល់ដីទៅឲ្យកូនក្តីខ្លួន ទើបអាចធ្វើការកាត់ឈ្មោះតាមនីតិវិធីបាន ហេតុនេះ ទើបកូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងមកតុលាការ ដើម្បីសុំឲ្យតុលាការចេញសាលក្រមសម្រេចដូចក្នុងកម្មវត្ថុបណ្តឹង ។

១១.យល់ឃើញថា តាមការពិនិត្យសេចក្តីថ្លែងការណ៍របស់ភាគី និងឯកសារភស្តុតាងដែលដាក់ជូនតុលាការពិនិត្យ ឃើញថា ដីមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ថេត និងប្រពន្ធឈ្មោះ [redacted]ចាន់នី ក្រោយមកឈ្មោះ [redacted] ថេត និងប្រពន្ធ បានព្រមព្រៀងលក់ដីខាងលើនេះទៅឲ្យឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក តាមរយៈកិច្ចសន្យាលេខ ៧៤៧ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ និងលិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវលេខ ៧៤៦ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ ដែលស៊ីសង្វាក់ទៅនឹងលិខិតបញ្ជាក់លេខ ៣៥ អប២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ របស់មេឃុំអូរដំបង២។

១២.យល់ឃើញថា កិច្ចសន្យាលេខ ៧៤៧ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ និងលិខិតផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនកិនស្រូវលេខ ៧៤៦ អប២ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១០ របស់គូភាគី បញ្ជាក់ថា ឈ្មោះ [redacted]



Scanned with CamScanner

ថេត និងប្រពន្ធឈ្មោះ [redacted] ចាន់នី ពិតជាបានព្រមព្រៀងផ្ទេរសិទ្ធិដី និងរោងម៉ាស៊ីនទៅឲ្យឈ្មោះ [redacted] ប៊ូ និងប្រពន្ធឈ្មោះ [redacted] យុក ស្របនិងមាត្រា ៥១៥ និងមាត្រា ៥១៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រាកដមែន។

១៣.ផ្អែកតាមសំអាងហេតុខាងលើ តុលាការគប្បីពិនិត្យសម្រេចតាមការទាមទាររបស់ដើមចោទ ។

១៤.ចំពោះ ប្រាក់ប្រដាប់ក្តី និងអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែដោយភាគីដើមចោទស្នើសុំទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

I.ទទួលស្គាល់សិទ្ធិអត្ថិភាពលើឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៥៧ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង។

II.ឲ្យឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៥៧ មានសិទ្ធិកាត់ផ្ទេរកម្មសិទ្ធិដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០២០៨០៩០៥-០៥៥២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ពីម្ចាស់កម្មសិទ្ធិករឈ្មោះ [redacted] ថេត និងនាង [redacted] ចាន់នី មកឲ្យឈ្មោះ [redacted] ប៊ូ ភេទប្រុស កើតឆ្នាំ១៩៨៣ និងប្រពន្ធឈ្មោះ [redacted] យុក កើតឆ្នាំ១៩៥៧ តាមនីតិវិធីជំនាញសុរិយោដី ។

III.ឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ ។

*សាលក្រមនេះជាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ចំពោះមុខមេធាវីតំណាងដោយអាណត្តិដើមចោទ និងកំបាំងមុខចុងចម្លើយ ប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ។*

*-បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។*

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

បាត់ដំបង ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

ក្រឡាបញ្ជី

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

[redacted]

បានផ្ទៀងផ្ទាត់ត្រឹមត្រូវតាមច្បាប់ដើម

បាត់ដំបង ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner